**BMI0030**

### សម្ភាសន៍ជាមួយឈ្មោះ អ៊ួ ជឿន ភេទប្រុស អាយុ៥១ឆ្នាំ
### មុខងារជំនាន់ខ្មែរក្រហម“ បើកបររថយន្ត”
### មុខងារបច្ចុប្បន្ន“កសិករ”
### ស្រុកកំណើតនៅភូមិអកអឹំ ឃុំ? ស្រុកបាភ្នំ ខេត្តព្រៃវែង
### រស់នៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
### ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០
### សម្ភាសន៍ដោយៈ សោម ប៊ុនថន
### ០០:៣៧:១៩
### ១៩ទំព័រ

ប៊ុនថនៈ ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូមានឈ្មោះអីដែរ?

ជឿនៈ ឈ្មោះ អ៊ួ ជឿន ។

ប៊ុនថនៈ ពូអាយុប៉ុន្មានហើយ?

ជឿនៈ អាយុ៥១ ។

ប៊ុនថនៈ ពូមានស្រុកកំណើតនៅណាដែរ?

ជឿនៈ ខ្ញុំនៅស្រុកបាភ្នំ ភូមិអកអឹំ ស្រុកបាភ្នំ ។

ប៊ុនថនៈ ខេត្តព្រៃវែង?

ជឿនៈ បាទ ។

ប៊ុនថនៈ ពូមានបងប្អូនប៉ុន្មាននាក់ពូ?

ជឿនៈ ខ្ញុំមានបងប្អូន៦ នាក់ ។

ប៊ុនថនៈ ពូកូនទីប៉ុន្មានពូ?

ជឿនៈ ខ្ញុំកូនទីពីរ ។

ប៊ុនថនៈ ស្រីប៉ុន្មានប្រុសប៉ុន្មានដែរ?

ជឿនៈ ស្រីបីប្រុសបី ។

ប៊ុនថនៈ ចឹងឪពុកម្ដាយពូនៅរស់ទេ?

ជឿនៈ ស្លាប់ទាំងអស់ ។

ប៊ុនថនៈ ស្លាប់ឆ្នាំណា?

ជឿនៈ ស្លាប់ប្រហែលជា៦ឆ្នាំមុនហ្នឹង ។

ប៊ុនថនៈ ស្លាប់ទាំងអស់តែម្តង?

ជឿនៈ ស្លាប់ទាំងអស់ ។

ប៊ុនថនៈ ស្លាប់ដោយសារជំងឺធម្មតា?

ជឿនៈ ជំងឺធម្មតាចាស់ជរា ។

ប៊ុនថនៈ កាលពូនៅភូមិមានបានចូលរៀនអីទេ កាលនៅពីក្មេង?

ជឿនៈ រៀនបានតិចតួច រៀនបានតិចមែនទែនចេះអានអីមើល ។

ប៊ុនថនៈ រៀនបានប៉ុន្មានឆ្នាំដែរ?

ជឿនៈ រៀនមែនទែនសម័យហ្នឹងស្រុកគេកើតសង្គ្រាមនោះ ព្រោះខ្ញុំស្រុកកើតសង្គ្រាមខ្ញុំមានអាយុ១៣-១៤ហើយហ្នឹងដល់ពេលកើតសង្គ្រាមរវល់តែឈប់ហ្នឹងមានយន្តហោះទម្លាក់អីនោះយើងមិនឈប់ ។

ប៊ុនថនៈ បាទ ។

ជឿនៈ រៀននៅសាលាវត្ត ។

ប៊ុនថនៈ រៀននៅក្នុងភូមិពូ?

ជឿនៈ កាលមុនរៀននៅវត្តដល់ក្រោយមករៀនក្នុងភូមិធ្វើសាលាតាមភូមិតូចៗ រៀនក្រោមផ្ទះរៀនអីហ្នឹងសម័យហ្នឹង ។

ប៊ុនថនៈ បាទ! រៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ជឿនៈ សម័យហ្នឹងរៀនដល់ថ្នាក់ទី១១ដែលដឹង កាលហ្នឹងរាប់ពីធំមកតូចតើសម័យហ្នឹងស្មើថ្នាក់ទី១ទី២យើងឥឡូវដឹង ។

ប៊ុនថនៈ ចឹង១២ទី១១ត្រូវថ្នាក់ទី២ចឹង?

ជឿនៈ បាទ ។

ប៊ុនថនៈ កាលពូឈប់រៀនហ្នឹងមកនៅផ្ទះបុក៏?

ជឿនៈ ឈប់រៀននៅផ្ទះជាមួយម៉ែឪនេះ ។

ប៊ុនថនៈ នៅជាមួយម៉ែឪរហូតដល់ពេលណា?

ជឿនៈ នៅរហូតដល់ឆ្នាំ៧៥បានគេឲ្យខ្ញុំមកនៅភ្នំពេញ កាលគេរំដោះភ្នំពេញបានគេឲ្យខ្ញុំមកនៅភ្នំពេញ ។

ប៊ុនថនៈ ពូមកនៅខាងណាវិញភ្នំពេញ?

ជឿនៈ នៅភ្នំពេញខ្ញុំនៅអូរដើម ។

ប៊ុនថន៖ កាលពូនៅអូរជឹមហ្នឹងនៅខាងផ្នែកអីវិញលោកពូ?

ជឿន៖ គេឲ្យខ្ញុំរៀនបើកបរដំបូង ។

ប៊ុនថន៖ បើកបរ?

ជឿន៖ បាទ! បើកឡានបើកអីដំបូង ។

ប៊ុនថន៖ រៀនយូរទេពូ?

ជឿន៖ រៀនអត់មានយូរប៉ុន្មានទេ រៀនបណ្ដើរគេឲ្យធ្វើជាងជងអីផង ។

ប៊ុនថន៖ ចឹងពូចេះជាងទៀត?

ជឿន៖ រៀនជាងចេះតែយើងចេះវាមិនច្បាស់ យើងរៀនបានតិចតួចពេក ។

ប៊ុនថន៖ ជាងឡានពូ?

ជឿន៖ ជាងឡាន ។

ប៊ុនថន៖ ចឹងរាល់ថ្ងៃនៅចេះទេពូ?

ជឿន៖ រាល់ថ្ងៃខ្ញុំអត់ទេ មិនដែលបានធ្វើផង ។

ប៊ុនថន៖ តែបើកឡាននៅចេះ?

ជឿន៖ ចេះបើកបានតិចតួចអី ។

ប៊ុនថន៖ យើងរៀនបើឡានអីវិញ?

ជឿន៖ ឡានធម្មតាឡានដឹកដីអីហ្នឹង ។

ប៊ុនថន៖ រៀនយូរដែលទេកាលនៅហ្នឹង?

ជឿន៖ រៀនមានយូរប៉ុន្មានទេ រៀនធ្វើជាងជងរៀនបើកឡានផង កាលហ្នឹងរៀនបើកសាកអីហ្នឹង ដល់ក្រោយមកបានគេឲ្យបើកដឹកដីដឹកអី ។

ប៊ុនថន៖ អ្នករៀនច្រើនទេ?

ជឿន៖ រៀនច្រើនកាលសម័យនោះ អ្នករៀនច្រើនណាស់ ។

ប៊ុនថន៖ រៀនហើយពូធ្វើអីទៀតពូ?

ជឿន៖ រៀនហើយដល់ក្រោយមកគេឲ្យខ្ញុំមកភ្ជួរដី គេឲ្យខ្ញុំមកភ្ជួរដីនៅបាត់ដំបង បើកត្រាក់ទ័រ ។

ប៊ុនថន៖ បាទ ។

ជឿន៖ ដល់ឆ្នាំ៧៦ គេឲ្យខ្ញុំទៅភ្នំពេញវិញ ។

ប៊ុនថន៖ ៧៦?

ជឿន៖ បានខ្ញុំទៅភ្នំពេញរហូតដល់៧៩ ឆ្នាំ៧៦-៧៧-៧៨បានគេឲ្យខ្ញុំទៅនៅកំពង់សោម ។

ប៊ុនថន៖ បាទ ។

ជឿនៈ គេឲ្យខ្ញុំធ្វើផ្លូវទេះភ្លើង កាលសម័យហ្នឹងគេធ្វើផ្លូវទេះភ្លើងថ្មីមួយ ។

ប៊ុនថនៈ បាទ ។

ជឿនៈ ពីភ្នំពេញទៅកំពង់សោមហ្នឹង ខ្ញុំបានប្រឡូកការងារធ្វើផ្លូវទេះភ្លើងថ្មីជាមួយគេហ្នឹងខ្ញុំបរអាសានីឈូសដីហ្នឹង ។

ប៊ុនថនៈ អាប៊ុលដូស័រហ្នឹង?

ជឿនៈ បាទ! ខ្ញុំបរអាហ្នឹងទៅដល់កំពង់សោមបានដល់ឆ្នាំ៧៩ខ្ញុំរត់ រត់ពី៧៩មកហ្នឹង ។

ប៊ុនថនៈ បាទ ។

ជឿនៈ រត់តាមតានី តាមអីទេខ្ញុំភ្លេចអស់ហើយមកតាមកោះកុងអីហ្នឹងបានរត់មកខ្ញុំមកនៅហ្នឹងមកនៅខ្មែរមនៅគ្រាន់ខ្ញុំនៅហ្នឹងរហូត ។

ប៊ុនថនៈ ខ្មែរមហ្នឹងនៅប៉ៃលិនឬមួយនៅខេត្តណា?

ជឿនៈ ខ្មែរមសព្វថ្ងៃនៅខេត្តបាត់ដំបង ស្រុកកំរៀងដល់ក្រោយមកធ្វើទ័ពជាមួយគេហ្នឹង ។

ប៊ុនថនៈ រត់ប៉ុន្មានថ្ងៃពីកំពង់សោមមក?

ជឿនៈ យូរណាស់មិនដឹងជាប៉ុន្មានថ្ងៃ មិនអាចចាំបានយូរដែលហ្នឹង ដើរកាត់ព្រៃកាត់អីមករាប់ខែនោះបានខ្ញុំមកនៅព្រំដែនហ្នឹងបានធ្វើទ័ពអីជាមួយគេ ។

ប៊ុនថនៈ នៅខ្មែរមហ្នឹងពូ?

ជឿនៈ បាទ!នៅខ្មែរមចូលធ្វើទ័ពធ្វើជាទាហាន នៅក្មេងៗគេមិនសូវឲ្យទៅមុខអីផង នៅក្រោយដាំបាយឲ្យគេហូប ។

ប៊ុនថនៈ បាទ ។

ជឿនៈ ដល់ក្រោយមកបានខ្ញុំត្រូវរបួស ផ្ទុះមីន ។

ប៊ុនថនៈ តែមានគ្រោះថ្នាក់អីទេ?

ជឿនៈ គ្រោះថ្នាក់បាក់ជើងនេះ ត្រូវរបួសចឹងទៅក៏ខ្ញុំឈប់ទៅមានប្រពន្ធអីទៅចេះតែនៅក្រោយគេទៅគេមិនសូវប្រើទៅណាទេ ។

ប៊ុនថនៈ បាទ ។

ជឿនៈ នៅចឹងរហូតដល់សព្វថ្ងៃហ្នឹងទៅ ។

ប៊ុនថនៈ ចឹងពូកាលផ្ទុះមីនត្រូវតែជើងទេ ពូ?

ជឿនៈ ត្រូវជើងត្រូវភ្នែកត្រូវខ្លួនត្រូវអី ។

ប៊ុនថនៈ តែអត់មានធ្វើទុកអីដល់រាល់ថ្ងៃទេ?

ជឿនៈ រាល់ថ្ងៃវាធ្វើទុកដែលហ្នឹង ខ្វះចុកដៃចុកជើងដែរ ព្រោះនៅអំបែងវះអត់អស់ណាស់ ។

ប៊ុនថនៈ បាទ ។

ជឿនៈ តែវាមិនបានធ្វើទុកធ្ងន់ធ្ងរអីវាអត់មានទេ ។

ប៊ុនថនៈ ចឹងពូដឹងថាចុកហ្នឹងមកពីអំបែង?

ជឿនៈ បាទ!មកពីអំបែងព្រោះយើងដឹង មកអំបែងវាធ្វើទុកខ្ញុំត្រូវយូរតាំងពីឆ្នាំ៨១អីនោះ ។

ប៊ុនថនៈ តាំងពី៨១?

ជឿនៈ បាទ!ហើយក្រោយពីត្រូវហ្នឹងខ្ញុំទៅដេកពេទ្យនៅខាវដាងនោះ ពេទ្យនៅខាវដាងគេហៅពេទ្យអង្គការ ។

ប៊ុនថនៈ បាទ ។

ជឿនៈ ពេលជាបានខ្ញុំត្រឡប់មកវិញ ។

ប៊ុនថនៈ ពេលជាទៅនៅខ្មែរ?

ជឿនៈ ត្រឡប់មកនៅនេះវិញ នៅហ្នឹងម៉ាខ្សែហ្នឹងវិញ កាលហ្នឹងអង្គភាពដូរពីខ្មែរមកនៅនេះណាស់ ។

ប៊ុនថនៈ បាទ ។

ជឿនៈ ខ្ញុំមកនៅនេះវិញ ។

ប៊ុនថនៈ កាលរត់មកហ្នឹងមានគ្នាច្រើនទេពូ?

ជឿនៈ ច្រើនមនុស្សរាប់ពាន់នាក់នោះ ពួកកម្មកររោងចក្រហ្នឹងមានប្រុសមានស្រីច្រើនណាស់ ។

ប៊ុនថនៈ ចុះមកច្រើនចឹងយើងមកតាមៗគ្នាពូ?

ជឿនៈ មិនមានមកតាមគ្នាទេ បើយើងនិយាយឲ្យទៀងត្រង់ទៅមេគេនាំមកតែម្តង ដូចថាមេប្រធានរោងចក្រចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

ជឿនៈ គេនាំមកឲ្យយើង បើដាច់ដោចក៏យើងមកមិនបានព្រោះមិនដឹងបាយទឹកនៅណា កាលហ្នឹងយើងមកតាមអង្គភាពចឹងទៅ ។

ប៊ុនថនៈ ចឹងហូបចុកយ៉ាងម៉េចដែលបើយើងមកច្រើនចឹង?

ជឿនៈ ហូបចុកដល់យើងមកច្រើនមានការខ្វះខាតច្រើន បើនិយាយពីហូបចុកវាលំបាកមែនទែន យើងមកដល់ព្រៃហ្នឹងយើងហូបក្តួចហូបត្រពាំងអីចឹងទៅ ធម្មតាអង្គរគេមានឲ្យតិចតួច ដល់ក្រោយមកមានខាងកាកបាទគេឲ្យទៅយើងមានហូបគ្រប់គ្រាន់ ។

ប៊ុនថនៈ ចឹងដូចថានៅតាមផ្លូវចឹងមានអ្នកស្លាប់អីចឹងទៅ?

ជឿនៈ កាល៧៩មាន ស្លាប់ដោយប្រការថាអត់បាយក៏ថាបានម្យ៉ាងយើងជាតំបន់គ្រុនចាញ់

ណាស់ ។

ប៊ុនថន៖ បាទ ។

ជឿន៖ យើងមិនមានផ្ទះអីយើងដេកតែកៅស៊ូ សំខាន់គ្រុនចាញ់ទេ កាលហ្នឹងហើយព្រៃកាលហ្នឹងមានប្រឡោះដើរតូចៗណាស់ ព្រៃងងឹតឈើងតែម្តងព្រៃធំ យើងដើរព្រៃវាសម្បូរតំបន់គ្រុនចាញ់ផង ថាឲ្យមានគ្រោះថ្នាក់ដោយស្អីវាមិនមានទេ សម័យហ្នឹងអត់បាយហូបហើយហ្នឹងគ្រុនចាញ់ ។

ប៊ុនថន៖ បាទ ។

ជឿន៖ គ្រុនចាញ់ខ្លាំងណាស់កាលសម័យហ្នឹង ក្រោយពីគ្រុនចាញ់ក្រោយមកមានកាកបាទមានមនុស្សធម៌គេជួយចឹងទៅ យើងបន្ថយការស្លាប់បានច្រើនដែរ ។

ប៊ុនថន៖ បាទ ។

ជឿន៖ មានពេទ្យមានអីមើលត្រឹមត្រូវ ។

ប៊ុនថន៖ ចឹងកាលពូមកពីកោះកុងហ្នឹងមកខ្មែរតែម្តង?

ជឿន៖ អត់ទេ ខ្ញុំរត់ពី៧៩ហ្នឹង ខ្ញុំមកនៅខ្មែរ ។

ប៊ុនថន៖ នៅខ្មែរយូរទេ?

ជឿន៖ នៅខ្មែរបានបួនទៅប្រាំខែដែលហ្នឹង ។

ប៊ុនថន៖ ចឹងនៅខ្មែរហ្នឹងជាប់ថៃតែម្តងពូ?

ជឿន៖ ជាប់ដូចយើងចឹងដែរ ។

ប៊ុនថន៖ ចឹងចេញចូលថៃអីបានទេពូ?

ជឿន៖ ចេញចូលបានតាមរយៈយើងមានលុយមានកាក់អី ទៅទិញផាវ៉ាន់ហូបចុកពីថៃចឹងទៅណាស់ ។

ប៊ុនថន៖ បាទ ។

ជឿន៖ យើងដាក់អន្ទាក់បានសត្វអី យើងទៅលក់ឲ្យថៃចឹងទៅណាស់ ។

ប៊ុនថន៖ បាទ ។

ជឿន៖ បានលុយទិញអីហូបទៅ ។

ប៊ុនថន៖ និយាយចឹងយើងដោះស្រាយជីវភាពខ្លួនយើងផ្ទាល់តែម្តងបុក៏?

ជឿន៖ មិនផ្ទាល់ទេ កាលសម័យហ្នឹង កាលហ្នឹងមានរបៀបគេមានមេដូចថាបានអង្ករពីថៃមកគេហៅយើងទៅយកមកចែកគ្នាហូបទៅ តាមគេកំណត់ឲ្យ ។

ប៊ុនថន៖ បាទ ។

ជឿនៈ តាមគេកំណត់ឲ្យយើងរបបហូបចុកណាស់ ។

ប៊ុនថនៈ ចឹងដោះដូរចឹងយើងយកមកចែកគ្នា?

ជឿនៈ យកមកចែកគ្នាហូបដូចថាមនុស្សសម័យហ្នឹងនៅចង្រ្កង់វាល្អដែរ ។

ប៊ុនថនៈ បាទ ។

ជឿនៈ វាសុទ្ធតែអត់មានម៉ែឳរៀងៗខ្លួន ស្រឡាញ់គ្នារាប់អានគ្នាចឹងទៅ ។

ប៊ុនថនៈ ចឹងភាគច្រើនមិនទាន់មានគ្រួសារតែម្ដង?

ជឿនៈ អត់ អត់មានទេ ។

ប៊ុនថនៈ ចឹងក្រោយពីពួចូលទ័ពហើយហ្នឹងបានពូមកនៅម៉ាឡៃ?

ជឿនៈ វាមែនទែនខ្ញុំចូលទ័ពតាំងពីហ្នឹងមក ដល់ក្រោយមកបានខ្ញុំមកនៅម៉ាឡៃយើងនេះ ។

ប៊ុនថនៈ បាទ ។

ជឿនៈ មកនៅម៉ាឡៃរហូតទាល់តែឆ្នាំ៨៥ បានខ្ញុំមានប្រពន្ធមានកូន ។

ប៊ុនថនៈ ចឹងមកដល់ម៉ាឡៃដំបូងហ្នឹងម៉ាឡៃយ៉ាងម៉េចដែរ និយាយវាព្រៃឬមានមនុស្សរស់នៅហើយ?

ជឿនៈ ព្រៃដូចគ្នា៧៩ហ្នឹង យើងរត់មកកាលពីមុនមិនមានមនុស្សនៅទេ ដល់យើងមកនៅបានមានមនុស្សនៅចឹងទៅ ដល់ហើយទៅមានព្រៃធម្មតាតែនាំគ្នាធ្វើកូនផ្ទះតូចៗនៅ ។

ប៊ុនថនៈ បាទ ។

ជឿនៈ ព្រោះថា កន្លែងនោះមិនមានលំហ្នឹងណាស់ ។

ប៊ុនថនៈ បាទ ។

ជឿនៈ ដូនកាលខ្លាចទាហានខាងក្នុងវាវៃបុក យើងរត់ទៅថៃអីចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

ជឿនៈ យើងអត់មានផ្ទះអីមាំមួនទេ ដូចសព្វថ្ងៃចឹងទេ ។

ប៊ុនថនៈ មានកូនខ្ទម?

ជឿនៈ កូនខ្ទមតូចៗហ្នឹង យើងម៉ាល្មមនៅសមហ្នឹង យើងដាក់ឈើប្រក់ស្បៅអីទៅវាសមរម្យនៅ ។

ប៊ុនថនៈ បាទ ។

ជឿនៈ តែដល់ក្រោយពីហ្នឹងមកដល់ឆ្នាំ៨៣-៨៤-៨៥ហ្នឹងអាហ្នឹង ជីវភាពលែងសូវខ្វះហើយ ដូចខ្ញុំនិយាយចឹងមានកាកបាទមនុស្សធម៌គេជួយចឹង ។

ប៊ុនថនៈ បាទ ។

ជឿនៈ នៅពេលយើងឈឺទៅមានមណ្ឌលសុខភាពគេជួយទៅ បើយើងឈឺស្កាត់ធ្ងន់ធ្ងរគ្រុនធំអីហ្នឹង មានពេទ្យអង្គការគេយកទៅដេកពេទ្យនៅខាវដាងអីទៅ។

ប៊ុនថនៈ នៅជំរំ?

ជឿនៈ បាទ! នៅជំរំខាវដាង។

ប៊ុនថនៈ ពីហ្នឹងទៅខាវដាងឆ្ងាយទេ?

ជឿនៈ ពីហ្នឹងទៅខាវដាងឆ្ងាយត្រូវឆ្លងកាត់ស្រុកអារាញ់មួយទៀតបានដល់ ខ្ញុំវាអត់បានដឹងច្បាស់ដែរ ខ្ញុំដឹងថាឆ្លងកាត់ស្រុកអារាញ់។

ប៊ុនថនៈ ចឹងជិះប៉ុន្មានម៉ោងដែលជិះពីហ្នឹងទៅ?

ជឿនៈ តាមខ្ញុំស្មានហើយប្រហែលជាមួយម៉ោងកន្លះទៅពីរម៉ោងដែរ តែថាៗទៅស្រុកគេសម័យហ្នឹងព្រំដែនត្រូវការតម្រួតទាហានវាច្រើន រោងយាមវាត្រូវត្រួតត្រូវអី។

ប៊ុនថនៈ តម្រួតខាងណាវិញ?

ជឿនៈ តម្រួតថៃ។

ប៊ុនថនៈ គេនៅតាមព្រំដែនដែរ?

ជឿនៈ តម្រួតគេនៅតាមព្រំដែនដែរ ឡានអង្គការហ្នឹងថៃត្រូវត្រួតតាមព្រំដែនដែរ ជារឿងច្បាប់របស់គេយើងមិនដឹងណាស់។

ប៊ុនថនៈ បាទ។

ជឿនៈ តែដល់ក្រោយពីហ្នឹងមក ដល់សម័យសមាហរណ៍កម្មក៏យើងបានកាប់ព្រៃធ្វើស្រែធ្វើចំការអារឈើមកធ្វើផ្ទះអីនៅទៅណាស់។

ប៊ុនថនៈ បាទ។

ជឿនៈ ចឹងបានថាស្រុកនេះខ្ញុំពិនិត្យមើលរឿងផ្ទះធំវាអត់សំខាន់ទេ បើកាលណាស្រុកព្រៃឈើ បើយើងមិនខំកាប់ធ្វើនៅវាអត់មាន។

ប៊ុនថនៈ បាទ។

ជឿនៈ ចេះតែតស៊ូទៅ ឃើញផ្ទះធំៗឃើញថាមានលុយមានកាក់ប៉ុន្មានមិនមានទេ ព្រោះផ្ទះខ្ញុំធំដែលមិនមែនតូចណា នោះផ្ទះខ្ញុំអាដំបូលក្រហមៗនោះបាំងស្លឹកខ្នោរនោះ។

ប៊ុនថនៈ បាទ! ធំ។

ជឿនៈ ខ្ញុំតស៊ូធ្វើសន្សំលុយកាក់ជាមួយប្រពន្ធធ្វើចំការក្រោយមកស៊ីឈ្នួលបកស្រែចំការគេផង។

ប៊ុនថនៈ ចឹងឲ្យតែខំមាន?

ជឿនៈ បាទ។

ប៊ុនថន: តែពូនិយាយថាកាប់ចំការបានដីច្រើនទេ?

ជឿន: ដីមានប្រហែលជា៤០រ៉ៃ ។

ប៊ុនថន: ចឹងបានប៉ុន្មានហិចតាដែរ?

ជឿន: ក្នុងមួយហិចតាមាន៦រ៉ៃ ។

ប៊ុនថន: ចឹងមួយហិចតា៦រ៉ៃ?

ជឿន: បាទ ។

ប៊ុនថន: ចឹង៤០រ៉ៃបាន៧ហិចតាពូ?

ជឿន: បាទ ។

ប៊ុនថន: ចឹងធ្វើចំការបានហើយ?

ជឿន: បាទ ។

ប៊ុនថន: និយាយថា កាលពូចូលដំបូងនិយាយថាគេបែងចែកកង១តែម្តង?

ជឿន: បាទ!ហ្នឹងជាកងទ័ពតែម្តង ។

ប៊ុនថន: កាលហ្នឹងមានមេដឹកនាំអីដែរទេ?

ជឿន: មានមេ យើងធ្វើទាហានត្រូវមានមេហើយ ដូចថាធ្វើទាហានសម័យនោះវាបើប្រៀបទៅវាដូចថាយើងមកហើយវាជ្រុលដំណើរហើយមិនដឹងជាទៅណា ត្រឡប់ទៅផ្ទះវិញមិនរួចដូចថាចូលធ្វើទ័ពអីហ្នឹងគេទៅ ។

ប៊ុនថន: បាទ ។

ជឿន: បើយើងត្រឡប់ទៅក្រោយវិញក៏ទៅមិនបាន ស្រុកយើងឆ្ងាយយើងទៅ ទៅមិនរួចសំខាន់យើងអត់មានថវិការអីទៅ យើងទៅមិនដល់ស្រុកចេះតែនៅៗរហូតដល់សព្វថ្ងៃហ្នឹងកើតកូនចៅផ្ទះសំបែងនៅនេះទៅ ។

ប៊ុនថន: ចឹងពូមាននឹកស្រុកដែរ?

ជឿន: ស្រុកនឹកតែខ្ញុំស្រុកទៅលេងមិនចោលស្រុកទេ ស្រុកកំណើតដូចខ្ញុំនិយាយចឹងយើងបែកពីស្រុកយូរយើងរកផ្ទះមិនឃើញទេ ក្រោយមកមានផ្លូវអីស្រួលបួលស្រុកទេសគេមានច្បាប់ទំលាប់ត្រឹមត្រូវយើងស្រួលដើរហើរចឹងវាអត់មានបញ្ហាអីទេ ។

ប៊ុនថន: បាទ ។

ជឿន: មុនដំបូងយើងមិនហ៊ានទៅទេ ម្យ៉ាងខ្លាចថាយើងជួបឥទ្ធិពលអតីតខ្មែរក្រហមអីចឹង ខ្លាចគេរករឿងអីយើងណាស់ ។

ប៊ុនថន: បាទ ។

ជឿនៈ ដល់ពេលកន្ទងមកដាក់ស្ដែងខ្ញុំទៅ គិតទៅខ្ញុំបែកពីស្រុកខ្ញុំតាំងពីឆ្នាំ៧៥ដល់សម័យសមាហរណ៍កម្មប៉ុន្មាន៩៦សមាហរណ៍កម្ម "អ្នកជិតនិយាយ៩៧" ជឿននិយាយវិញ កាល ៩៧ខ្ញុំទៅអត់មានពីណារករឿងខ្ញុំទេ ជារឿងធម្មតា គេគ្រាន់តែថាបែកពីស្រុកអីយូរអាហ្នឹងជាធម្មតាទេ យើងទៅនៅខាងណាយើងបំរើនយោបាយគេខាងហ្នឹងចឹង ។

ប៊ុនថនៈ បាទ ។

ជឿនៈ កាលទៅមានពីណារករឿង ដល់សម័យនេះខ្ញុំទៅពេលណាក៏បានគ្មានពីណារករឿងទេ ។

ប៊ុនថនៈ បាទ!ស្រុកយើងសេរីហើយ?

ជឿនៈ បាទ! កាលហ្នឹងខ្ញុំទៅលេងស្រុកខ្ញុំទៅជាកងទ័ព ខ្ញុំកាលហ្នឹងសមាហរណ៍កម្មហើយខ្ញុំនៅធ្វើទាហានដដែល កាលហ្នឹងគេបើកសំភារៈខេមរភូមិន្ទទៅ គេថាឯងធ្វើខ្មែរក្រហម ខ្ញុំថាមានធ្វើខ្មែរក្រហមណាមើលខោអាវខ្ញុំ ខេមរភូមិន្ទតើ ។

ប៊ុនថនៈ បាទ ។

ជឿនៈ ខ្ញុំថារឿងខាងលើៗរឿងខាងក្រោមៗរឿងកូនចៅទេ ដូចខ្ញុំបញ្ជាក់ហ្នឹងយើងនៅខាងណាបំរើនយោបាយខាងហ្នឹងហើយ ។

ប៊ុនថនៈ ចឹងពូមកដល់ម៉ាឡៃនេះនៅឆ្នាំណា?

ជឿនៈ មកដល់ម៉ាឡៃនេះនៅឆ្នាំ៨២ ។

ប៊ុនថនៈ ចឹងកាល៧៩-៨០-៨១ពូនៅខ្លែម?

ជឿនៈ បាទ!នៅខ្លែមនៅសំពៅលូនអង្គភាពគេចល័តចុះឡើងណាស់ ខ្ញុំមកនៅហ្នឹងឆ្នាំ៨២ជាន់ទឹកដីនេះនៅឆ្នាំ៨២ ។

ប៊ុនថនៈ កាលហ្នឹងមកច្រើនទេមករស់នៅ?

ជឿនៈ កាលហ្នឹងមកច្រើនមកមួយអង្គភាពមកច្រើន ។

ប៊ុនថនៈ នៅហ្នឹងគេហៅជាអង្គភាពឬជាកងពល?

ជឿនៈ កាលហ្នឹងគេនៅកងពល៤៥០ កងពលតា មេទាហានយើងសព្វថ្ងៃហ្នឹង ។

ប៊ុនថនៈ កងពលសុខ ភាពឬក៏?

ជឿនៈ បាទ!កងពលសុខ ភាពហ្នឹង៤៥០ គាត់ជាប្រធានកងពល ។

ប៊ុនថនៈ កាលមកដល់ដំបូងគេដាក់បន្ទាយនៅណាវិញ?

ជឿនៈ បន្ទាយគេបើគិតទៅខ្មែរក្រហមធ្វើសង្គ្រាមអត់មានបន្ទាយទេ គេគ្រាន់តែមានកន្លែងកងពលគេតូចៗចឹងទៅ ដូចថាប្រជុំមេទាហានអី ថាថ្មើជើងគេដាក់រាយទៅមួយកងៗគេដាក់រាយរហូត តាំងពីនេះទៅគេហៅខ្វាងរាប ទួលពគ្រអីហ្នឹង អូរសំព័រអីហ្នឹង ។

ប៊ុនថន:	បាទ ។

ជឿន:	គេដាក់រាយគ្នាតែតិចៗទេ ខ្មែរក្រហមធ្វើទាហានអត់ចេះមានបន្ទាយទេ ទីតាំងតូចៗទេ ត្រឹម៣០ទៅ៤០នាក់ បើថាឲ្យមមានទីតាំងមាំតែម្តងមិនមានទេ ។

ប៊ុនថន:	បាទ ។

ជឿន:	បើមាន មានតែកន្លែងគេនៅ បើថាកន្លែងទីតាំងមាំៗគេទីតាំងគេនៅក្រោយតែម្តងគេនៅ ដូចថាកន្លែងឃ្លាំងកន្លែងទ័ពកន្លែងសម្ភារគេណាស់ ។

ប៊ុនថន:	បាទ ។

ជឿន:	បន្ទាយខ្មែរក្រហមដើររកមិនមានទេ ខ្មែរក្រហមអត់មានទីតាំងពិតប្រាកដ បើនិយាយទៅពួកហ្នឹងពូកែដែលរបៀបធ្វើសង្គ្រាមឈ្លបវាមានតិចវាចល័តពូកែ ។

ប៊ុនថន:	បាទ ។

ជឿន:	អត់មានទីតាំងទេ ។

ប៊ុនថន:	ចឹងឃ្លាំងអីគេមាននៅខាងក្រោយទៀត?

ជឿន:	បាទ!ឃ្លាំងគេយកមកដាក់នៅក្រោយៗ ។

ប៊ុនថន:	នៅក្នុងដីថៃឬនៅក្នុងខ្មែរ?

ជឿន:	នៅក្នុងដីខ្មែរយើងហ្នឹង ។

ប៊ុនថន:	បាទ ។

ជឿន:	ដល់ពេលត្រូវការចឹងទៅ គេឲ្យអ្នកដឹកជញ្ជូនយកទៅមានឡានអីគេដឹកទៅឲ្យពួកទាហានចឹងទៅណាស់ ។

ប៊ុនថន:	បាទ!ចឹងកាលពូមកដល់នេះនៅឆ្នាំ៨២ហ្នឹងមានប្រជាជនដែរ?

ជឿន:	ប្រជាជនមានខ្លះ ខ្លះប្រជាជនខ្លះកងទ័ពសម័យហ្នឹងពីណានៅប្រជាជនក៏នៅទៅពីណាធ្វើកងទពក៏ធ្វើទៅគេអត់មានបន្ទុំយើងណា ។

ប៊ុនថន:	ប្រជាជនច្រើនទេពូ?

ជឿន:	ប្រជាជនច្រើនដែរ ប្រជាជនមានរាប់ម៉ឺននាក់នោះ ។

ប៊ុនថន:	ចឹងប្រជាជនបានស្បៀងអាហារមកពីណាវិញ?

ជឿន:	ស្បៀងបានមកពីអ្នកដឹកនាំគេចែក គេបានពីកាកបាទមកគេចែក និយាយរួមគេមានសត្ថិតិថាក្នុងភូមិមួយៗមានប្រជាជនប៉ុន្មាន យើងស្រង់យកទៅឲ្យខាងកាកបាទទៅគេដឹកសម្ភារមកតម្រូវតាមហ្នឹង តែយកមកគេចែកឲ្យប្រជាជន ដល់ថ្ងៃគេបើកអង្ករគេមកយកយើងទៅយកជិតកន្លែងស្ពានយើងនេះ ស្ពានឈើយើងនេះ ។

ប៊ុនថន៖ ស្ពានឈើនេះ?

ជឿន៖ បាទ!ស្ពានឈើនៅដីថៃហ្នឹង គេយកមកចែកឲ្យយើងទៅ ចេះតែទៅយកគេទៅ ដូចថាតាមភូមិអីគេរៀបជាក្រុមចែកមួយស្បោងៗម្នាក់ចឹងទៅ។

ប៊ុនថន៖ បាទ!ចឹងកន្លែងផ្តល់ស្បៀងអីគេបើកនៅដីថៃទេ?

ជឿន៖ បាទ!ដីថៃ អង្គការនៅដីថៃ។

ប៊ុនថន៖ ចឹងគេមិនយកចូលដល់នេះអត់ទេ?

ជឿន៖ អត់ទេ ព្រោះកាលហ្នឹងវាអត់មានស្ពានឆ្លងឡានចូលរួចណាស់។

ប៊ុនថន៖ ចឹងត្រូវការទៅបើកអីចូលទៅ?

ជឿន៖ បាទ!វាមានថ្ងៃគេ គេកំណត់ឲ្យមកបើកយើងមកបើក។

ប៊ុនថន៖ ចឹងពូមកហ្នឹងមានវៃគ្នាជាមួយទាហានខាងក្នុងដែរ?

ជឿន៖ មាន ចុះយើងធ្វើទាហានវាតែងតែប៉ះទង្គិចគ្នា កាលហ្នឹងភាគច្រើនមិនមានទាហានរដ្ឋាភិបាលទេ ច្រើនតែទាហានវៀតណាម។

ប៊ុនថន៖ បាទ។

ជឿន៖ ទាហានយួន។

ប៊ុនថន៖ បាទ។

ជឿន៖ កាលហ្នឹងវៃជាមួយទាហានវៀតណាម ក្រោយមកបានវៃជាមួយទាហានរដ្ឋាភិបាលហ្នឹង នៅពេលដែលយួនដកទៅស្រុកវាហើយមិននៅទាហានរដ្ឋាភិបាល។

ប៊ុនថន៖ បាទ។

ជឿន៖ វៃគ្នាបន្តិចបន្តួច។

ប៊ុនថន៖ ចឹងកាលវៃជាមួយវៀតណាមហ្នឹងមានវៃខ្លាំងដែរ?

ជឿន៖ វៃខ្លាំងតើ វៃកាលហ្នឹងទ្រុងទ្រាយធំ កាលហ្នឹងវៀតណាមឡើងមកច្រើន តែវៃភាគច្រើនគេមិនសូវវៃតាមព្រំដែនទេ ច្រើនវៃនៅខាងក្នុងសម័យនោះគេហៅជិតបវេលអីហ្នឹង នៅតាគង់អីរាល់ថ្ងៃហ្នឹងណាស់។

ប៊ុនថន៖ បាទ។

ជឿន៖ កន្លែងទីតាំងគេនៅហ្នឹង។

ប៊ុនថន៖ ចឹងពូនៅនេះដល់វៀតណាមដកហ្នឹងនៅម៉ាឡៃហ្នឹង?

ជឿន៖ ខ្ញុំនៅរហូតតាំងពីឆ្នាំ៨២មកខ្ញុំនៅរហូត។

ប៊ុនថន៖ តាំងពីឆ្នាំ៨២ដល់៨០ប៉ុន្មាន?

ជឿនៈ ៨២ដល់ក្រោយមកយួនវ៉ៃខ្លាំង៨៥រត់ទៅនៅដីថៃ ប្រហែលជា៩០មិនដឹងជាប៉ុន្មានទេ ៩៣មិនដឹងគេឲ្យមកនៅហ្នឹងវិញដល់សព្វថ្ងៃហ្នឹងវិញ ។

ប៊ុនថនៈ ទៅនៅដីថៃហ្នឹងពូទៅនៅណា?

ជឿនៈ ចូលទៅក្នុងដែលតែនៅក្នុងខេត្តស្រះកែវថៃហ្នឹង ។

ប៊ុនថនៈ នៅហ្នឹងគេហៅអីវិញពូ?

ជឿនៈ នៅដីថៃគេហៅ«១៨៥» ព្រោះយើងរត់ឆ្នាំ៨៥គេដាក់«១៨៥»យើងនៅដីថៃឆ្នាំ៨៥ ។

ប៊ុនថនៈ ពូទៅនៅហ្នឹងធ្វើការអីដែរ?

ជឿនៈ ទៅនៅហ្នឹងធ្វើទាហាន តែយើងនៅក្នុងដីថៃយើងមិនមានកាន់អាវុធអីទេ ។

ប៊ុនថនៈ បាទ ។

ជឿនៈ តែដល់គេត្រូវការយើងមកខាងមុខចឹងបានគេបញ្ជូនយើងមក ។

ប៊ុនថនៈ មានឡានដឹកមក?

ជឿនៈ បាទ ។

ប៊ុនថនៈ កាលហ្នឹងឡានថៃឬមួយឡានខ្មែរ?

ជឿនៈ កាលហ្នឹងដូចជាមិនមែនឡានខ្មែរទេ គ្រាន់តែថៃហ្នឹងជាអ្នកធ្វើការដែរ ព្រោះខ្មែរយះគេខាងលើយើងមិនបានដឹង ។

ប៊ុនថនៈ បាទ ។

ជឿនៈ ខ្មែរក្រហមត្រូវការពឹងពាក់ថៃដឹកជញ្ជូនទាហានដែរ ។

ប៊ុនថនៈ ពូនៅហ្នឹងប៉ុន្តែពូឡើងមកវ៉ៃ?

ជឿនៈ គេឲ្យមកនៅតាមព្រំដែន យើងមកប្រចាំការប្រចាំអី ។

ប៊ុនថនៈ ចឹងខាងវៀតណាមចូលមកដល់ក្នុងភូមិនេះតែម្ដង?

ជឿនៈ ដល់ឆ្នាំ៨៥ដល់ ។

ប៊ុនថនៈ ចឹងមកដល់ហ្នឹងចឹងខាងថៃមានត្រៀមកំលាំងនៅតាមព្រំដែនអីមានទេ?

ជឿនៈ ថៃមានតើ ។

ប៊ុនថនៈ ទាហានថៃដាក់មកដើម្បីពូ?

ជឿនៈ ទាហានថៃតាមមើលគេដាកលមកការពារទឹកដីគេ ថាគេចូលមកលូកលាន់ដីខ្មែរអីអត់មានទេ គេការពារទឹកដីគេ ។

ប៊ុនថនៈ ចឹងខាងវៀតណាមដែលវ៉ៃចូលដីថៃផុតអូរដែលពូ?

ជឿនៈ ដូចជាអត់មានទេ សម័យហ្នឹងកន្លែងហ្នឹងដូចជាអត់មានទេ វាមកនៅត្រឹមៗអូរតាមព្រំ

ដែនធម្មតា បើធៀបទៅថៃដូចជារអត់មានទេ ។

ប៊ុនថន: ចឹងពូនៅក្នុងថៃហ្នឹងរហូតដល់ឆ្នាំ៩០ជាងបានពូមកវិញ?

ជឿន: បាទ!ដល់ឆ្នាំ៩០ជាង ។

ប៊ុនថន: ៩០ប៉ុន្មាន?

ជឿន: តាមខ្ញុំចាំបើមិន៩០គត់៩១ប៉ុណ្ណឹង ចន្លោះប៉ុណ្ណឹងឯង ។

ប៊ុនថន: ចឹងចូលមកហ្នឹងទាហានគេដកចេញពីហ្នឹងអស់ហើយបានពូចូលមក?

ជឿន: បាទ! គេដកចេញអស់ហើយ ។

ប៊ុនថន: គេដកទៅណា?

ជឿន: គេដកទៅក្នុងៗអស់ហើយ កាលហ្នឹងគេដកទៅក្នុងវិញតាមមើលជំនាន់គេព្រមព្រៀងគ្នាឲ្យយួនដកកងទ័ពចេញវិញហ្នឹងណាស់ ។

ប៊ុនថន: ៨៩វៀតណាមដកកងទ័ពចេញ?

ជឿន: ហ្នឹងហើយប្រហែលហ្នឹងឯង៨៩-៩១ហ្នឹងឯង កំឡុងឆ្នាំ៩០ហ្នឹងឯងខ្ញុំចាំមិនច្បាស់ដែរ ។

ប៊ុនថន: ដល់ហើយពូចូលមកនេះវិញ?

ជឿន: បាទ ។

ប៊ុនថន: ចូលមកហ្នឹងជាកងទ័ពដដែលឬមួយយ៉ាងម៉េច?

ជឿន: បាទ!ជាកងទ័ពធម្មតាយើងមានគ្រួសារសម័យហ្នឹងយើងមានគ្រួសារតែយើងមកមានអត្តភាពអីធម្មតាណាស់ ។

ប៊ុនថន: បាទ ។

ជឿន: គេឲ្យមកទាំងអសលគ្នា ។

ប៊ុនថន: ចឹងផ្ទះដីធ្លី?

ជឿន: ដីធ្លីអីក៏យើងមិនទាន់មានដែរ យើងគ្រាន់តែធ្វើតិចៗហ្នឹង យើងមិនទាន់កាប់ចំការអីធំដុំទេនៅតូចតាចដែលទេ ។

ប៊ុនថន: បាទ ។

ជឿន: សម័យហ្នឹង ។

ប៊ុនថន: ចឹងនៅសម័យនេះគេបើកឲ្យទេ?

ជឿន: បាទ! បើកហូបចុកអីគេឲ្យ ។

ប៊ុនថន: ចឹងពូការឆ្នាំណា?

ជឿន: ខ្ញុំការឆ្នាំ៨៥ ។

ប៊ុនថន: ការនៅនេះឬនៅថៃពូ?

ជឿន: ការនៅថៃ ។

ប៊ុនថន: គ្រួសារលោកពូគាត់ធ្វើអីដែលកាលហ្នឹង?

ជឿន: ប្រពន្ធខ្ញុំនៅកងនារីដឹកជញ្ជូន ។

ប៊ុនថន: ចឹងបានគ្នាតាំងពីហ្នឹងមក?

ជឿន: បាទ! បានគ្នាតាំងពីហ្នឹងមក ។

ប៊ុនថន: ចឹងផ្ទះដីធ្លីអីពូបានក្រោយមកទេពូ?

ជឿន: បាទ!ផ្ទះដីធ្លីបានក្រោយមក ។

ប៊ុនថន: ឆ្នាំណាពូមកនៅ?

ជឿន: បើគិតទៅខ្ញុំនៅតាំងឆ្នាំ៩៣ ធ្វើផ្ទះបាននៅក្រោយមកខ្ញុំរុះផ្ទះខ្ញុំធំដែល៥-៦ដែល៩៣ ក្រោយមកខ្ញុំរុះធ្វើសារថ្មី ទៅធ្វើផ្ទះនៅសព្វថ្ងៃនេះ ។

ប៊ុនថន: បាទ ។

ជឿន: នៅនេះមានរបបដីធ្លីគេចែកអ្នកដឹកនាំសម័យនោះ គេចែកឲ្យយើងតាមគ្រួសារអីតែយើងគ្រប់គ្រងដីធ្លីខ្លួនយើងបានមិនបានយើងមិនដឹងទេ ។

ប៊ុនថន: បាទ ។

ជឿន: បើយើងលក់ដូរអីយើងមិនដឹងទេណាស់ ។

ប៊ុនថន: បាទ ។

ជឿន: តែមានរបបដីធ្លីគេចែកឲ្យយើងតែយើងកាប់យកទៅ ។

ប៊ុនថន: ចឹងគេមានកំណត់ទេកាប់បានប៉ុណ្ណាយកប៉ុណ្ណឹង?

ជឿន: សម័យហ្នឹងគេកំណត់ដែរ ថាម្នាក់ប៉ុន្មានហាត់ៗចឹងទៅយើងកាប់ទៅ បើយើងមានលុយមានកាក់អីយើងទៅវៀតវៃត្រង់ណាបានទៀត ក៏យើងទៅៗ ស្រេចតែយើងដែលសម័យនោះយើងមានលុយច្រើនយើងកាប់បានច្រើនទៅ ព្រោះដីវាធំ ។

ប៊ុនថន: ហើយព្រៃដីចំការពូត្រាយខ្លួនឯងដែរ?

ជឿន: ត្រាយខ្លួនយើងខ្លះទៅយើងចូលបន្ទាស់ដៃគ្នាកាប់ទៅម្នាក់ម្តងចឹងទៅ ដូចថាយើងធ្វើកងទ័ពចឹងបើយើងចង់កាប់ព្រៃហ្នឹងយើងបបួលគ្នាទៅកាប់ទៅ កាប់អ្នកនេះហើយចឹងកាប់អ្នកនោះទៅណាស់ ជួយកាប់គ្នាទៅណាស់ ។

ប៊ុនថន: បាទ ។

ជឿន: កាលហ្នឹងនៅចងក្រងគ្នាល្អដែលកាលសម័យហ្នឹង ។

ប៊ុនថន៖ ចឹងមានមីនទេ?

ជឿន៖ កាប់ចំការរឿងជួបប្រទះរឿងមីនដូចជាមិនមានទេ មិនជួបទេ ។

ប៊ុនថន៖ ចឹងតាមនេះមានទេ?

ជឿន៖ តាមហ្នឹងមាន ពីដើមមីន"ក៥"អីពួកវៀតណាមដាក់មីនពីរបីខែ្សធ្វើរបងលួសអីទៀតនោះ កាលហ្នឹង ។

ប៊ុនថន៖ ចឹងមីនកាលឆ្នាំណាកើតមានហ្នឹងពូ?

ជឿន៖ គ្រាប់មីនតាមមើលវាពិបាកណាស់ កាលជំនាន់ខ្មែរក្រហមនៅគេដាក់ តែគេដាក់ទៅក្នុងៗ ណាស់ ។

ប៊ុនថន៖ បាទ ។

ជឿន៖ តែដល់ក្រោយមកទាហានខាងក្នុងគេដាក់ការពារព្រំដែនដែរ ព្រោះគេដឹងកំលាំងខ្មែរ ក្រហមចូលដីថៃ ខ្លាចពួកហ្នឹងឡើងមកវិញគេដាក់ការពារព្រំដែនដែរ ។

ប៊ុនថន៖ បាទ ។

ជឿន៖ តែមីនកាលហ្នឹងទាហានខាងក្នុងដាក់ច្រើន ។

ប៊ុនថន៖ ចឹងខាងក្នុងដាក់ច្រើន?

ជឿន៖ បាទ ។

ប៊ុនថន៖ ខាងខ្សែព្រំដែន?

ជឿន៖ បាទ ។

ប៊ុនថន៖ តែដំបូងគេខាងកំលាំងតស៊ូចូលដាក់ខាងក្នុង?

ជឿន៖ បាទ!កំលាំងតស៊ូគេចូលដាក់នៅខាងក្នុង ដល់កំលាំងគេវិញពីក្នុងមកគេដាក់តាមព្រំដែនវិញ ទៅ ។

ប៊ុនថន៖ ចឹងដីចំការអីពូមានដែលកាប់ចំទេ?

ជឿន៖ អត់ដែលចំផង ។

ប៊ុនថន៖ ចឹងដើងលោកពូរបួសដោយសារអីលោកពូ?

ជឿន៖ ខ្ញុំរបួសដោយសារមីន ។

ប៊ុនថន៖ ចឹងរបួសនៅពេលណាដែរ?

ជឿន៖ ខ្ញុំរបួសនៅឆ្នាំ៨១ ។

ប៊ុនថន៖ កាលហ្នឹងពូមកនៅហ្នឹងហើយឬនៅណា?

ជឿន៖ មិនទាន់មកនៅហ្នឹងផង កាលហ្នឹងខ្ញុំនៅសំពៅលូន ។

ប៊ុនថន៖ កាលហ្នឹងមានមីនដែរ?

ជឿន៖ មាន ។

ប៊ុនថន៖ ចឹងមីនហ្នឹងថុះខាងណាជាអ្នកដាក់ដែរ?

ជឿន៖ មីនហ្នឹងមិនដឹងជាខាងណាខាងណីដាក់យើងមិនដឹង ។

ប៊ុនថន៖ កាលហ្នឹងពូឡើងទៅវ៉ៃពូ?

ជឿន៖ ខ្ញុំអត់ទៅវ៉ៃទេ កាលហ្នឹងគេឲ្យដើរបាតទីតាំង ។

ប៊ុនថន៖ បាទ ។

ជឿន៖ គេឲ្យយើងដើរបាតរាល់ថ្ងៃមិនដែលខានទេ តាមកងតាមក្រុមអីចេះតែទៅធម្មតាចឹង ។

ប៊ុនថន៖ បាទ!ចឹងគ្រោះថ្នាក់តែពូអ្នកដើរជាមួយពូអត់អីទេ?

ជឿន៖ គ្រោះថ្នាក់ដែរ គ្រោះថ្នាក់ស្លាប់ម្នាក់របួសប្រហែលជា៧នាក់ផាប់មួយ ។

ប៊ុនថន៖ ចឹងចង់សួរពូថា ភូមិសាស្ត្រនៅម៉ាឡៃមានឈើមានផ្លូវដូចហ្នឹងទេ?

ជឿន៖ អត់មានផង ។

ប៊ុនថន៖ សុទ្ធតែព្រៃសុទ្ធ?

ជឿន៖ បាទ!សុទ្ធតែព្រៃមានតែផ្លូវដើរជើងតូចៗហ្នឹង ។

ប៊ុនថន៖ ចឹងនៅហ្នឹងសារតាំងកើតនៅឆ្នាំណា?

ជឿន៖ សារតាំងមិនដឹងជាកើតឆ្នាំណា ។

ប៊ុនថន៖ ពូមកមាននៅ?

ជឿន៖ ខ្ញុំមកមានហើយ គេហៅសារតាំងៗកើតឆ្នាំណាយើងមិនដឹង ។

ប៊ុនថន៖ ចឹងឥឡូវនៅតែគេហៅសារតាំងពូ?

ជឿន៖ បាទ!ឥឡូវគេនៅហៅចឹងដែរ ។

ប៊ុនថន៖ ចឹងរហូតដល់ឆ្នាំណាសមាហរណ៍កម្ម?

ជឿន៖ សមាហរណ៍កម្មឆ្នាំ៩៦ដឹង ខ្ញុំចាំមិនបានដែរ ។

ប៊ុនថន៖ ៩៦?

ជឿន៖ បាទ!ដូចចាំវាមិនច្បាស់ខ្ញុំ ។

ប៊ុនថន៖ ចឹងចង់សួរពូថា មុនសមាហរណ៍កម្មនិងក្រោយសមាហរណ៍កម្មចង់និយាយថាការរស់នៅរបររកស៊ីគិតថាប្រែប្រួលយ៉ាងម៉េចដែរ?

ជឿន៖ បាទ!មានការខុសប្លែកគ្នាច្រើន កាលសម័យយើងមិនទាន់សមាហរណ៍កម្មយើងក៏មិនទាន់រកស៊ីអីធំដុំដែរ ដល់ៗធ្វើសមាហរណ៍កម្មហើយការរកស៊ីយើងធ្វើបានតាមចិត្ត ។

ប៊ុនថន: បាទ ។

ជឿន: ជឿសវាងយើងរកស៊ីអំពើខុសច្បាប់ ។

ប៊ុនថន: បាទ ។

ជឿន: បើយើងរកស៊ីត្រូវច្បាប់គេអត់មានបញ្ហាអីទេ វាស្រួលជាងស្រួលរស់នៅអី អាហ្នឹងតាមតែយើង យើងរកអីបានរកទៅជារឿងរបស់យើង ។

ប៊ុនថន: បាទ!ចឹងខ្ញុំចង់សួរត្រឡប់ទៅក្រោយវិញ កាលពូចេញពីស្រុកកំណើតនៅឆ្នាំណា?

ជឿន: ឆ្នាំ៧៥ ។

ប៊ុនថន: ៧៥ហ្នឹងតែម្តង?

ជឿន: បាទ ។

ប៊ុនថន: ចឹងកាលពីតូចពូឈប់រៀនហើយពូនៅភូមិហ្នឹងរហូត?

ជឿន: បាទ ។

ប៊ុនថន: កាល៧៥ពូអាយុប៉ុន្មានហើយ?

ជឿន: ខ្ញុំកាលហ្នឹងប្រហែលជាអាយុ១៤-១៥ឆ្នាំ ។

ប៊ុនថន: ចឹងកាលពូបែកកាលឆ្នាំ៧៥ហ្នឹងពូមានដែលទាក់ទងទៅរកគ្រួសារដែលពូ?

ជឿន: អត់ទេ បែករហូតអត់មានដឹងដំណឹងអីរហូត ទាល់តែសម័យសមាហរណ៍កម្ម ។

ប៊ុនថន: ចឹងពូមានមិត្តភក្តិជួបគ្នាពីភូមិអីមកទេ?

ជឿន: អត់មានទេ ។

ប៊ុនថន: ដាច់តែឯងតែម្តង?

ជឿន: បាទ ។

ប៊ុនថន: សមាហរណ៍កម្មហើយឆ្នាំណាពូទៅស្រុក?

ជឿន: មិនដឹងជាឆ្នាំណា តែខ្ញុំដឹងថាសមាហរណ៍កម្មហើយខ្ញុំទៅលេងស្រុកបានម្តង ។

ប៊ុនថន: គាត់នៅស្គាល់ទេពូ បងប្អូនឪពុកម្តាយអី?

ជឿន: ស្គាល់ តែខ្ញុំមិនស្គាល់ខ្ញុំរកផ្ទះអត់ឃើញ វាបែកយូរពេក ។

ប៊ុនថន: ចឹងធ្វើម៉េចរកទៅស្រែកសួរគេពូ?

ជឿន: បាទ!ដើរសួរគេបែកយូរឆ្នាំហើយប្អូនដបម្ភៃឆ្នាំដឹង ។

ប៊ុនថន: បាទ ។

ជឿន: តាំងពី៧៥មកសមាហរណ៍កម្ម ។

ប៊ុនថន: តែបងប្អូននៅជុំគ្នាដែរពូ?

ជឿនៈ បាទ!បងប្អូនខ្ញុំនៅជុំគ្នា ។

ប៊ុនថនៈ អត់មានអ្នកបាត់បង់អីទេ?

ជឿនៈ អត់មានបាត់បង់ទេ បងប្អូនខ្ញុំនៅរស់អត់មានថាបាត់បង់ស្លាប់ដោយសារប្រការណាមួយ អត់មានទេ ។

ប៊ុនថនៈ បាទ!ចឹងនៅជួបជុំគ្នា?

ជឿនៈ បាទ!ជួបជុំគ្នាទាំងអស់ ។

ប៊ុនថនៈ ចឹងចង់សួរថានៅពេលជួបជំបូងមានអារម្មណ៍យ៉ាងម៉េចដែលពូ?

ជឿនៈ អារម្មណ៍មានអី ដូចថារកអីនិយាយមិនកើត ដូចថាវាអរខ្លាំងពេក ។

ប៊ុនថនៈ ចឹងខ្ញុំអត់មានអីសួរពូច្រើនទៀតទេ ។

ជឿនៈ បាទ ។

ប៊ុនថនៈ ចឹងអរគុណច្រើន ។

ជឿនៈ បាទ ។

**«ចប់»**